**មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា**
**Cambodian Center for Human Rights**

# សេចក្តីប្រកាសព័ត៌មាន ម.ស.ម.ក

ភ្នំពេញ ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៨

## សកម្មជនបរិស្ថានលោក វ៉ែន អៀត ត្រូវបានគេលបបាញ់នៅតំបន់អារ៉ែង ប៉ុន្តែមិនមានរងរបួស

| | |
|---|---|
| *កាលបរិច្ឆេទនៃហេតុការណ៍ ៖* | *ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៨* |
| *ឈ្មោះ ៖* | *វ៉ែន អៀត* |
| *ប្រភេទនៃសកម្មជន ៖* | *សកម្មជនផ្នែកបរិស្ថាន* |
| *ទីតាំង ៖* | *ខេត្តកោះកុង* |
| *ប្រភេទនៃការគំរាមកំហែង ៖* | *ការគំរាមកំហែងដល់អាយុជីវិត និងការប៉ុនប៉ងបាញ់សម្លាប់* |

កាលពីថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៨ វេលាម៉ោងប្រហែលជា១០យប់ សកម្មជនបរិស្ថានលោក វ៉ែន អៀត ត្រូវបានគេលបបាញ់ប្រហារនៅឯផ្ទះរបស់លោកស្ថិតក្នុងភូមិច្រកឫស្សី ឃុំជំនាប់ ស្រុកថ្មបាំង ខេត្តកោះកុង តែជាសំណាងល្អដែលលោកមិនត្រូវរងរបួសនោះទេ។ លោក វ៉ែន អៀត បានស្នាក់នៅផ្ទះរបស់លោកជាមួយនឹងមិត្តភក្តិម្នាក់ នៅពេលដែលគេលបបាញ់លោក ខណៈពេលដែលលោកទៅបន្ទប់ទឹកនៅឯក្រោយផ្ទះ។ ដោយសារតែស្ថានភាពងងឹតពេក លោក វ៉ែន អៀត និងមិត្តភក្តិរបស់លោកមិនអាចមើលឃើញអ្នកដែលលបបាញ់លោកនោះទេ ហើយក៏មិនអាចកំណត់បានថាមានមនុស្សតែម្នាក់ជាអ្នកបាញ់ប្រហារ ឬច្រើននាក់នោះដែរ។ ប្រជាពលរដ្ឋនៅក្នុងភូមិក៏បានអះអាងថាបានលឺគ្រាប់កាំភ្លើង ហើយពួកគាត់បានបន្ថែមថាគ្រាប់កាំភ្លើងនោះគឺលឺចេញពីទិសនៃផ្ទះរបស់លោក វ៉ែន អៀត។

លោក វ៉ែន អៀត គឺជាប្អូនប្រុសបង្កើតរបស់លោក វ៉ែន វ៉ន់ ដែលជាសកម្មជនបរិស្ថានដ៏ល្បីម្នាក់ ដែលបានចូលរួមយ៉ាងសកម្មក្នុងការការពារសិទ្ធិមនុស្ស និងបរិស្ថាននៅក្នុងតំបន់អារ៉ែង ខេត្តកោះកុង។ នៅឆ្នាំ២០១៣ លោក វ៉ែន អៀត ធ្លាប់ចូលរួមតស៊ូមតិប្រឆាំងនឹងការសាងសង់ទំនប់វារីអគ្គីសនីនៅតំបន់អារ៉ែង ហើយបច្ចុប្បន្នលោកចូលរួមយ៉ាងសកម្មផងដែរក្នុងការចុះល្បាតព្រៃជាមួយនឹងសកម្មជនបរិស្ថានផ្សេងទៀតដើម្បីប្រឆាំងនឹងការដឹកជញ្ជូនឈើខុសច្បាប់។ លោក វ៉ែន អៀត ក៏កំពុងធ្វើការគាំទ្រក្រុមជនជាតិដើមភាគតិច "ជង" ក្នុងការចុះបញ្ជីទទួលស្គាល់អត្តសញ្ញាណជនជាតិដើមភាគតិចផងដែរ។ លោក វ៉ែន អៀត ក៏ធ្លាប់ជាបេក្ខជនរបស់គណបក្សសង្គ្រោះជាតិក្នុងអំឡុងពេលបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១៧ ផងដែរ ប៉ុន្តែលោកមិនមាន

ការពាក់ព័ន្ធជាមួយគណបក្សនយោបាយនេះទៀតឡើយ បន្ទាប់ពីគណបក្សនេះត្រូវបានរំលាយដោយសាលដីការបស់តុលាការកំពូលនៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៧ មក។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៨ លោក វ៉ែន អៀត ត្រូវបានជំទប់ឃុំម្នាក់ប្រាប់ថា "អន្ទិតអៀតឯងមិនយូរទេ បន្តិចទៀតនឹងលាចាកលោកនេះហើយ បើសិនជាអន្ទិតអៀតឯងគេចខ្លួនទៅនៅស្រុកខាងប្រពន្ធក៏ដោយ" ដែលនេះលោកគិតថាជាការគំរាមសម្លាប់។ ហេតុការណ៍នេះបានកើតឡើងនៅប៉ុន្មានថ្ងៃក្រោយបន្ទាប់ពីលោកធ្វើដំណើរទៅរាជធានីភ្នំពេញជាមួយសមាជិកសហគមន៍ជនជាតិដើមភាគតិចជង ១០ នាក់ផ្សេងទៀតដើម្បីដាក់សំណើសុំការចុះបញ្ជីទទួលស្គាល់អត្តសញ្ញាណជនជាតិដើមភាគតិច ហើយមួយសប្តាហ៍បន្ទាប់មកមានបុរសម្នាក់បានដឹងពាក្យសំដីដាក់លោកថាគោលបំណងពិតដែលលោក វ៉ែន អៀត ទៅរាជធានីភ្នំពេញគឺដើម្បីចូលរួមការប្រមូលផ្តុំរបស់ចលនាគណៈបក្សសង្គ្រោះជាតិ។ បើទោះបីជាលោក វ៉ែន អៀត បានដាក់ពាក្យបណ្តឹងទៅប៉ូលិសប៉ុស្តិ៍ បន្ទាប់ពីមានការគំរាមកំហែងពីសំណាក់ជំទប់ឃុំក៏ដោយ ក៏មិនមានការចាត់វិធានការណ៍ណាមួយផងដែរ។ បន្ទាប់ពីគ្មានចំណាត់ការពីសំណាក់អាជ្ញាធរ និងដោយមានការភ័យខ្លាចចំពោះសុវត្ថិភាពរបស់លោក និងក្រុមគ្រួសារ លោកជាមួយប្រពន្ធ និងកូនប្រុសម្នាក់ក៏បានគេចខ្លួនចេញពីផ្ទះមួយរយៈ។ ទោះជាយ៉ាងណា លោកបានត្រលប់មកផ្ទះវិញ នៅថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៨ បន្ទាប់ពីលោកទទួលបានទូរស័ព្ទពីស្នងការនៃស្រុកថ្មបាំងដើម្បីមកបំភ្លឺពាក់ព័ន្ធនឹងបណ្តឹងដែលលោកបានដាក់ទៅប៉ុស្តិ៍ប៉ូលិស ដោយទុកគ្រួសាររបស់លោកឱ្យនៅកន្លែងមានសុវត្ថិភាពផ្សេងមួយទៀត។ បន្ទាប់ពីមានការពិភាក្សារវាងលោក វ៉ែន អៀត និងជំទប់ឃុំនៅថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៨ រួចមក ជំទប់ឃុំបានបញ្ជាក់ថាពាក្យដែលលោកនិយាយគំរាមគឺគ្រាន់តែជាការលេងសើចប៉ុណ្ណោះ ហើយជំទប់ឃុំក៏មានការធានានូវសុវត្ថិភាពរបស់ វ៉ែន អៀត និងក្រុមគ្រួសាររបស់លោកផងដែរ។ ថ្វីបើមានការធានានេះក៏ដោយ ក៏នៅតែមានការបាញ់ប្រហារទៅលើលោក វ៉ែន អៀត ដែលជាការគំរាមកំហែងមួយផ្សេងទៀត ហើយវាអាក្រក់បំផុត គឺការប៉ុនប៉ងធ្វើឱ្យមានរបួសធ្ងន់ធ្ងរ ឬក៏សម្លាប់លោកតែម្តង។

ទាំងការគំរាមសម្លាប់ និងការបាញ់ប្រហារទាំងពីរនេះ ទំនងបណ្តាលមកពីការជាប់ពាក់ព័ន្ធទៅលើសកម្មភាពរបស់ វ៉ែន អៀត ដែលលោកគឺជាសកម្មជនបរិស្ថាន និងសិទ្ធិមនុស្ស។ លើសពីនេះ ការប៉ុនប៉ងបាញ់ប្រហារនេះគឺជាការប៉ុនប៉ងដល់អាយុជីវិតរបស់ វ៉ែន អៀត ផ្ទាល់តែម្តង។ ការគំរាមកំហែងទាំងពីរនេះ ទាមទារឱ្យមានការស៊ើបអង្កេតជាបន្ទាន់ដោយមានតម្លាភាព និងមិនលម្អៀងពីសំណាក់អាជ្ញាធរ ក៏ដូចជាចាត់វិធានការជាបន្ទាន់ដើម្បីធានានូវសុវត្ថិភាពរបស់ វ៉ែន អៀត ព្រមទាំងក្រុមគ្រួសាររបស់លោក។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង ម.ស.ម.ក តាមរយៈទូរស័ព្ទលេខ ៖ ០២៣ ៧២៦ ៩០១ និង អ៊ីម៉ែល ៖** info@cchrcambodia.org ។